ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

**សំណុំរឿងព្រហ្មទណ្ឌ**

លេខៈ ៦០

ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១

**សាលដីកា**

លេខៈ ១១៣ ក្រV «វ»

ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ភ្នំពេញនាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅៈ

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

**ឯកឧត្តម** [redacted] **ប្រធានក្រុមប្រឹក្សា**

**លោកស្រី** [redacted] **ចៅក្រមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក** [redacted] **ព្រះរាជអាជ្ញា**

**ក្រឡាបញ្ជីសវនាការ**

**លោកស្រី** [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦០ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ លើៈ

១-ជនជាប់ចោទឈ្មោះ[redacted] ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីបេឡាជាតិ ទីកន្លែងកំណើតនៅភូមិកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល [redacted] សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ[redacted] (រស់) ម្តាយឈ្មោះ[redacted] (រស់) ប្រពន្ធឈ្មោះ[redacted] (រស់) មានកូនចំនួន០១នាក់ ទោសពីមុនគ្មាន ។ **(ប្តឹងឧទ្ធរណ៍)**

២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ [redacted] ភូមិព្រៃតាឡី ឃុំត្រពាំងធំខាងជើង ស្រុកត្រាំងកក់ ខេត្តតាកែវ ។

__ជាប់ចោទពីបទ__ ៖ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទប្រុស អាយុ២០ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិក្រឡា ឃុំប៉ុយ ស្រុកអូរជុំ ខេត្តរតនគីរី ។

-មានមេធាវី [redacted] តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។



ផ្លូវលោកតាក្រហមក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

ឯរឿងហេតុមានដូចតទៅៈ

សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទមានដូចខាងក្រោមៈ

កាលពីឆ្នាំ២០១៥ មានការប្រកាសប្រឡងជ្រើសរើស មន្ត្រីក្របខណ្ឌ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដោយឈ្មោះ [redacted]មិញ បានដាក់ពាក្យប្រឡងធម្មតា បន្ទាប់ពីដាក់ពាក្យប្រឡងរួចរាល់ហើយ ក៏មានឈ្មោះ [redacted]ចិត្ត ទាក់ទងមកឈ្មោះ[redacted]មិញ ជាច្រើនដង និងលួងលោមថា ប្រសិនជាចង់ប្រឡងជាប់ គាត់អាចជួយទាក់ទងគេ ដើម្បីជួយឈ្មោះ [redacted]មិញ ឱ្យប្រឡងជាប់ តែឈ្មោះ[redacted]មិញ ត្រូវបង់ប្រាក់ឱ្យគេ ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ)ដុល្លារ ។ ដោយជឿការលួងលោម នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៥ ឈ្មោះ[redacted]មិញ បានប្រគល់ប្រាក់ចំនួន២.៥០០ (ពីរពាន់ប្រាំរយ)ដុល្លារ ទៅឱ្យឈ្មោះ [redacted]ចិត្ត ។ បន្ទាប់មកពេលប្រឡងចប់ចេញលទ្ធផល ក៏ស្រាប់តែឈ្មោះ [redacted]មិញ ធ្លាក់ ហើយឈ្មោះ[redacted]ញ បានទាក់ទងទៅឈ្មោះ [redacted]ចិត្ត (មិនចាំលេខ)តែទាក់ទងមិនចូល បន្ទាប់មកទៀតក៏ស្រាប់តែមានឈ្មោះ [redacted]ចេង បានប្រើប្រាស់ទូរស័ព្ទលេខ ០៧០ ៣៥៥ ៥៥៧ ទាក់ទងមកឈ្មោះ [redacted]មិញ ឱ្យផ្ញើប្រាក់បន្ថែមជាច្រើនដង សរុបចំនួន ១.២០០ (មួយពាន់ពីររយ)ដុល្លារ ដើម្បីយកទៅដោះស្រាយបញ្ហានៅមន្ទីរប្រឆាំងអំពើពុករលួយ ដើម្បីឱ្យឈ្មោះ[redacted]មិញ មានឈ្មោះជាប់វិញ ពេលនោះឈ្មោះ [redacted]មិញ បានផ្ញើប្រាក់ឱ្យឈ្មោះ [redacted]ចេង ហើយជាលទ្ធផលឈ្មោះ [redacted]មិញ មិនបានទទួលអ្វីនោះទេ ហើយថែមទាំងព្យាយាមទាក់ទងទៅឈ្មោះ [redacted]ចិត្ត តែទាក់ទងមិនបាន ចំណែកឈ្មោះ[redacted]ចេង បានសន្យាថា នឹងសងប្រាក់ឱ្យឈ្មោះ[redacted]មិញ វិញ ក៏មិនឃើញឈ្មោះ [redacted]ចេង ចូលមកដោះស្រាយជាមួយឈ្មោះ[redacted]មិញ រហូតដល់ពេលបច្ចុប្បន្ន ទើបឈ្មោះ[redacted]មិញ ដាក់ពាក្យបណ្តឹងមកកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការ ។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥០៨៧ "ត" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ÷**

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]ចិត្ត ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១៨(ដប់ប្រាំបី)ខែ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០(ពីរលាន)រៀល ពីបទៈ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ចេង ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១(មួយ)ឆ្នាំ ពីបទៈ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។ តែទោសនេះត្រូវអនុវត្តព្យួរទាំងស្រុង ។

៣-ឱ្យឈ្មោះ [redacted]ចិត្ត សងប្រាក់ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ)ដុល្លារអាមេរិក និងសំណងជំងឺចិត្តចំនួន ៤.០០០.០០០ (បួនលាន)រៀល ឱ្យទៅដើមបណ្តឹងឈ្មោះ [redacted]មិញ ។ការទាមទារលើសពីនេះច្រានចោល ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**ក្រុមប្រឹក្សាជំនុំជម្រះ សាលាឧទ្ធរណ៍ភ្នំពេញ**

**យល់ឃើញថា ÷**

១/.បណ្តឹងឧទ្ធរណ៍លេខ ១២០២ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់មេធ[redacted]ណ្ណៈ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]ចេង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥០៨៧ "ក" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី២ និងទី៤ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងមាត្រា ៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ភ្នំពេញ ទទួលជំនុំជម្រះបាន ។

២/.តាមលទ្ធផលដេញដោលនាពេលសវនាការឃើញថា៖ កាលពីឆ្នាំ២០១៥ ឈ្មោះ[redacted]ចិត្ត បានលួងលោមឈ្មោះ [redacted]មិញ បើចង់ប្រឡងជាប់គេទាក់ទងឱ្យ តែត្រូវបង់ប្រាក់ឱ្យគេចំនួន ២.៥០០ $ បន្ទាប់មកចេញលទ្ធផលធ្លាក់ ក៏ឈ្មោះ[redacted]ចេង បានប្រើប្រាស់ទូរស័ព្ទលេខ ០៧០ ៣៥៥ ៥៥៧ ទាក់ទងមកឈ្មោះ[redacted]មិញ ឱ្យផ្ញើប្រាក់បន្ថែមជាច្រើនដង សរុបចំនួន ១.២០០ (មួយពាន់ពីររយ)ដុល្លារ ដើម្បីយកទៅដោះស្រាយបញ្ហានៅមន្ទីរប្រឆាំងអំពើពុករលួយ ដើម្បីឱ្យឈ្មោះ[redacted]មិញ មានឈ្មោះជាប់វិញ ពេលនោះឈ្មោះ [redacted]មិញ បានផ្ញើប្រាក់ឱ្យឈ្មោះ[redacted]ចេង ហើយជាលទ្ធផលឈ្មោះ[redacted]មិញ មិនបានទទួលអ្វីនោះទេ ដោយឈ្មោះ[redacted]ចេង បានសន្យាថា នឹងសងប្រាក់ឱ្យឈ្មោ[redacted]មិញ វិញ ក៏មិនឃើញឈ្មោះ[redacted]ចេង ចូលមកដោះស្រាយជាមួយឈ្មោះ[redacted]មិញ រហូតដល់ពេលបច្ចុប្បន្ន ប្រាកដមែន ដែលជាទម្រង់មួយនៃអំពើមានជាតុផ្សំ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted]ចេង ពីបទ៖ ឆបោក តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ដូចមានខ្លឹមសារក្នុងផ្នែកសំអាងហេតុ នៃសាលក្រមរបស់សាលាដំបូងបញ្ជាក់ស្រាប់ ហើយក្រុមប្រឹក្សាជំនុំជម្រះ ឯកភាពនឹងសំអាងហេតុទាំងនេះ ដោយពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៣/.តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ពាក់ព័ន្ធនៅក្នុងរឿងនេះ តំណាងមហាអយ្យការយល់ឃើញថា សេចក្តីសម្រេចរបស់សាលាដំបូងមានលក្ខណៈសមស្រប ដូច្នេះ តំណាងមហាអយ្យការ ទុកជូនក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យ និងសម្រេច ។

៤/.ចំណុចទី២ និងទី៤ នៃសាលក្រមព្រហ្មទណ្ឌលេខ ៥០៨៧ "ក" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

៤-ឱ្យឈ្មោះ[redacted]ចេង សងប្រាក់ចំនួន ១.២០០ (មួយពាន់ពីររយ)ដុល្លារអាមេរិក និងសំណងជំងឺចិត្តចំនួន ២.០០០.០០០ (ពីរលាន)រៀល ឱ្យទៅដើមបណ្តឹងឈ្មោះ [redacted]ញ ។ ការទាមទារលើសពីនេះច្រានចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ចិត្ត និងជនជាប់ចោទឈ្មោះ[redacted]ចេង និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ញ ប្រកាសជាសាធារណនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-**បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ ១២០២ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់មេធាវី[redacted] វណ្ណៈ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]ចេង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥០៨៧ "ក" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី២ និងទី៤ នៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** របាយការណ៍រឿងចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមរបាយការណ៍ សាលាឧទ្ធរណ៍ភ្នំពេញ។

-**បានឃើញ** សេចក្តីសន្និដ្ឋានចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ[redacted]ចេង (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ញ (អវត្តមាន)

-មេធាវី[redacted]ណ្ណ តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី (វត្តមាន)

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន

ពាក់ព័ន្ធនៅក្នុងរឿងនេះ តំណាងមហាអយ្យការ យល់ឃើញថា សេចក្តីសម្រេចរបស់សាលាដំបូងមានលក្ខណៈសមស្រប ដូច្នេះ តំណាងមហាអយ្យការ ទុកជូនក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យ និងសម្រេច ។

## មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន

មេធាវី [redacted]ណ្ណ ធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានសិក្សាលើសំណុំរឿង និងស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការរួចមក ឃើញថា នៅក្នុងសាលក្រមព្រហ្មទណ្ឌលេខ ៥០៨៧ "ក" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ បានរកឃើញពិរុទ្ធលើឈ្មោះ [redacted] វិចិត្ត និងឈ្មោះ[redacted]ចង ពិតជាបានប្រព្រឹត្តបទល្មើស ឆបោក ប្រាកដមែន ហើយការសម្រេចនេះមានលក្ខណៈត្រឹមត្រូវ។ ម្យ៉ាងទៀត ខាងកូនក្តីរបស់ខ្លួនក៏មិនបានប្តឹងឧទ្ធរណ៍ដែរ ដូច្នេះ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលក្រមទុកជាបានការដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១/.ទទួលបណ្តឹងឧទ្ធរណ៍លេខ ១២០២ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់មេធា[redacted]វណ្ណៈការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]ចង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២/.តម្កល់ចំណុចទី២ និងទី៤ នៃសាលក្រមព្រហ្មទណ្ឌលេខ ៥០៨៧ "ក" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទ ។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា៖ [redacted] | ហត្ថលេខា[redacted] | ហត្ថលេខា៖ [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១៥កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០២៣

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]